**ក្រុងមិតុយ៉ុ**

# សេចក្ដីជូនដំណឹងអំពីការចាក់វ៉ាក់សាំងជំងឺកូវីដ-១៩




ថ្លៃចាក់វ៉ាក់សាំង
**ឥតគិតថ្លៃ**
(ចំណាយសាធារណៈទាំងស្រុង)

## លំដាប់លំដោយរហូតដល់ការចាក់វ៉ាក់សាំង

គិតត្រឹមខែកក្កដាឆ្នាំ2021 នៅក្នុងការចាក់វ៉ាក់សាំងនៅទីតាំងចាក់វ៉ាក់សាំងជាក្រុមនិងនៅគ្រឹះស្ថានវេជ្ជសាស្ត្រក្នុងក្រុងមិតុយ៉ុ វ៉ាក់សាំងPfizer ត្រូវបានប្រើប្រាស់។

## 1 បំពេញលិខិតស្ទង់មតិអំពីបំណងចាក់វ៉ាក់សាំង (ឬបំពេញតាមវេបសាយ)

សូមគូស☑ត្រង់កន្លែងដែលត្រូវលក្ខខណ្ឌនៅក្នុងលិខិតក្នុងស្រោមសំបុត្រ។

【ខ្លឹមសារនៃការស្ទង់មតិ】

1 មានបំណងចាក់វ៉ាក់សាំងឬទេ

2 មានជំងឺប្រចាំកាយឬទេ

3 ទីតាំងចាក់វ៉ាក់សាំងដែលចង់ទៅចាក់

**អ្នកអាចបំពេញតាមវេបសាយ។ លេខប័ណ្ណចាក់វ៉ាក់សាំង សូមបំពេញលេខរបស់សាមីខ្លួនកុំខានធ្វើយ៉ាងណាកុំឲ្យខុស។ បើបំពេញខុស យើងអាចនឹងមិនអាចទទួលការចុះឈ្មោះរបស់អ្នក។ ករណីបំពេញតាមវេបសាយ មិនចាំបាច់ឆ្លើយតបលិខិតនេះទេ។**

**QR កូដ**

* ករណីបានចាក់វ៉ាក់សាំងរួចហើយ មិនចាំបាច់ឆ្លើយតបទេ។
* ទីតាំងចាក់វ៉ាក់សាំងនិងពេលវេលា នឹងត្រូវកំណត់ជូនដោយរដ្ឋបាលក្រុង។
* ចំពោះអ្នកមានជំងឺប្រចាំកាយ សូមសរសេរលេខគ្រឹះស្ថានវេជ្ជសាស្ត្រ(សូមមើលឯកសារភ្ជាប់) ដែលអ្នកកំពុងទទួលការព្យាបាល។ គួរបញ្ជាក់ថា អាចមានករណីដែលអ្នកមិនអាចទទួលការចាក់វ៉ាក់សាំងនៅគ្រឹះស្ថានវេជ្ជសាស្ត្រដែលកំពុងទទួលការព្យាបាល។ ហេតុនេះសូមជ្រាបជាព័ត៌មាន។

*<u>**សូមពិនិត្យបញ្ជាក់ថាលេខប័ណ្ណចាក់វ៉ាក់សាំងដែលមាននៅចុងខាងក្រោមខាងឆ្វេងនៃខ្នងលិខិត គឺជារបស់សាមីខ្លួនរួចហើយសឹម**</u>ផ្ដល់ចម្លើយនៅការស្ទង់មតិអំពីបំណងចាក់វ៉ាក់សាំង។
លេខប័ណ្ណចាក់វ៉ាក់សាំង គឺជាលេខ10ខ្ទង់ដែលមានសរសេរនៅលើប័ណ្ណចាក់វ៉ាក់សាំងនៅក្នុងស្រោមសំបុត្រ។

## 2 ផ្ញើលិខិតស្ទង់មតិអំពីបំណងចាក់វ៉ាក់សាំង(ឬបំពេញតាមវេបសាយ)

ក្រោយបំពេញរួច សូមដាក់ចូលក្នុងប្រអប់សំបុត្រប្រៃសណីយ៍។

## 3 រង់ចាំលិខិតបញ្ជាប់ការកក់ទុក⇒ចាក់វ៉ាក់សាំង

នៅពេលពេលវេលា/ទីតាំងកក់ទុកត្រូវបានកំណត់រួចរាល់ រដ្ឋបាលក្រុងនឹងផ្ញើលិខិតបញ្ជាប់ការកក់ទុក។
សូមចាក់វ៉ាក់សាំងនៅពេលវេលា ទីតាំងដែលត្រូវបានសរសេរនៅក្នុងលិខិតនោះ។

| របស់ត្រូវយកតាមខ្លួននៅថ្ងៃចាក់ | ●ប័ណ្ណចាក់វ៉ាក់សាំង (ភ្ជាប់ក្នុងស្រោមសំបុត្រ)<br>●ឯកសារបញ្ជាក់អត្តសញ្ញាណសាមីខ្លួន (ប័ណ្ណបើកបរ ប័ណ្ណធានារ៉ាប់រងសុខភាព ជាដើម)<br>●ឯកសារពិនិត្យសុខភាពជាមុន (សូមបំពេញឯកសារពិនិត្យសុខភាពជាមុន 1សន្លឹកក្នុងចំណោម2សន្លឹកដែលភ្ជាប់ក្នុងស្រោមសំបុត្រហើយយកមកតាមខ្លួន)<br>●សៀវភៅកំណត់ត្រាការប្រើប្រាស់ថ្នាំ (សម្រាប់តែអ្នកដែលមាន) |
|---|---|



នៅពេលទៅចាក់ សូមពាក់ម៉ាសនិងស្លៀកសម្លៀកបំពាក់ដែលងាយស្រួលលាត់បញ្ចេញស្មារ ដូចជា "**អាវដៃខ្លី**" ជាដើម។

* នៅថ្ងៃចាក់វ៉ាក់សាំង សូមវាស់កម្ដៅនៅផ្ទះហើយប្រសិនបើលេចចេញច្បាស់ថាក្ដៅខ្លួនឬមិនស្រួលខ្លួនជាដើម សូមជៀសវាងការចាក់វ៉ាក់សាំងហើយទាក់ទងទៅ**មជ្ឈមណ្ឌលសាកសួរព័ត៌មានតាមទូរសព្ទ ឬគ្រឹះស្ថានវេជ្ជសាស្ត្រដែលគ្រោងនឹងទៅចាក់វ៉ាក់សាំង**។
* ក្រោយចាក់វ៉ាក់សាំងរួច សូមរង់ចាំប្រហែល20នាទីដើម្បីតាមដានស្ថានភាព។
* ដើម្បីទទួលបានប្រសិទ្ធភាពវ៉ាក់សាំងឲ្យបានគ្រប់គ្រាន់ ចាំបាច់ត្រូវទទួលការចាក់វ៉ាក់សាំងប្រភេទដូចគ្នា 2 ដងដោយទុកគម្លាតពេលជាក់លាក់មួយ។ ក្រោយចាក់លើកទី 1 សូមពិនិត្យបញ្ជាក់ថ្ងៃកក់ទុកការចាក់វ៉ាក់វ៉ាក់សាំងលើកទី 2 រួចហើយសឹមទៅចាក់។
* ចំពោះ "ប័ណ្ណចាក់វ៉ាក់សាំង" ដែលភ្ជាប់ក្នុងស្រោមសំបុត្រ មាន "ប័ណ្ណចាក់វ៉ាក់សាំង" និង "លិខិតបញ្ជាក់ការចាក់វ៉ាក់សាំងបង្ការរួចរាល់" ក្នុងសន្លឹកតែមួយសម្រាប់ 2 លើក។ រាល់ពេល សូមយកតាមខ្លួនទាំងបែបនោះដោយកុំផ្ដាច់ចេញពីស៊ុម។


សាកសួរព័ត៌មាន　មជ្ឈមណ្ឌលសាកសួរព័ត៌មានតាមទូរសព្ទអំពីការចាក់វ៉ាក់សាំងកូវីដ-១៩ នៃក្រុងមិតុយ៉ុ
☎0875-63-3104

## ◎ ទីតាំងចាក់វ៉ាក់សាំងជាក្រុម

**អគារខាងលិចនៃសាលាក្រុងមិតុយ៉ុ**
2373-1 ស៊ិម៉ុកាត់ស៊ុម៉ា តាកាសិ-ឆូ ក្រុងមិតុយ៉ុ

**មណ្ឌលសុខភាពមិណុ-ឆូ**
2030-1 យ៉ុស៊ិហ្សឺអុុតស៊ុ មិណុ-ឆូ ក្រុងមិតុយ៉ុ

**យ៉ាម៉ាម៉ុតុ-ឆូ មជ្ឈមណ្ឌលកែលម្អបរិស្ថានភូមិកសិកម្ម**
375 សៃតានិស៊ិ យ៉ាម៉ាម៉ុតុ-ឆូ ក្រុងមិតុយ៉ុ

## ◎ ដូចម្តេចដែលហៅថាអ្នកមានជំងឺប្រចាំកាយ

ចំពោះអ្នកមានជំងឺប្រចាំកាយ គឺគ្រោងនឹងចាប់ផ្តើមការចាក់វ៉ាក់សាំងបន្ទាប់ពីមនុស្សវ័យចំណាស់។ អ្នកមានជំងឺប្រចាំកាយគឺជាអ្នកដែលចូលលក្ខខណ្ឌណាមួយខាងក្រោម (គិតត្រឹមថ្ងៃទី18 ខែមីនា ឆ្នាំ2021)។

1.អ្នកដែលមានជំងឺឬស្ថានភាពដូចខាងក្រោមហើយកំពុងទទួលការព្យាបាល/សម្រាកព្យាបាល

1. ជំងឺប្រដាប់ដង្ហើមរ៉ាំរ៉ៃ
2. ជំងឺបេះដូងរ៉ាំរ៉ៃ(រួមទាំងសម្ពាធឈាមខ្ពស់)
3. ជំងឺតម្រងនោមរ៉ាំរ៉ៃ
4. ជំងឺថ្លើមរ៉ាំរ៉ៃ(ជំងឺក្រិនថ្លើមជាដើម)
5. ជំងឺទឹកនោមផ្អែមដែលកំពុងព្យាបាលដោយអាំងស៊ុយលីន ថ្នាំលេប ឬជំងឺទឹកនោមផ្អែមដែលកើតរួមគ្នានឹងជំងឺផ្សេងទៀត
6. ជំងឺឈាម(យ៉ាងណាមិញ លើកលែងជំងឺខ្វះឈាមដោយសារខ្វះជាតិដែក)
7. ជំងឺដែលមុខងារប្រព័ន្ធភាពស៊ាំចុះខ្សោយ(រួមទាំងសាច់ដុះកាចដែលកំពុងព្យាបាល)
8. កំពុងទទួលការព្យាបាលដែលធ្វើឲ្យមុខងារប្រព័ន្ធភាពស៊ាំចុះខ្សោយដូចជា ស្តេរ៉ូអ៊ីតជាដើម
9. ជំងឺប្រព័ន្ធប្រសាទឬជំងឺប្រព័ន្ធប្រសាទសាច់ដុំដែលភ្ជាប់មកជាមួយនូវភាពមិនប្រក្រតីនៃប្រព័ន្ធភាពស៊ាំ
10. ស្ថានភាពដែលមុខងាររាងកាយចុះខ្សោយដោយសារជំងឺប្រព័ន្ធប្រសាទឬជំងឺប្រព័ន្ធប្រសាទសាច់ដុំជាមូលហេតុ(វិបត្តិដំណកដង្ហើមជាដើម)
11. ភាពមិនប្រក្រតីនៃក្រូម៉ូសូម
12. ពិការកាយសម្បទានិងសតិបញ្ញាធ្ងន់ធ្ងរ(ស្ថានភាពដែលមានពិការភាពអវយវៈកម្រិតធ្ងន់និងពិការភាពសតិបញ្ញាកម្រិតធ្ងន់រួមគ្នា)
13. អាការមិនដកដង្ហើមពេលគេង
14. ជំងឺផ្លូវចិត្តធ្ងន់ធ្ងរ(ករណីកំពុងសម្រាកនៅមន្ទីរពេទ្យដើម្បីព្យាបាលជំងឺផ្លូវចិត្ត មានសៀវភៅសុខុមាលភាពនៃសុខភាពជនពិការផ្លូវចិត្ត ឬចូលលក្ខខណ្ឌ "កម្រិតធ្ងន់និងជាប់ជាបន្ត" នៅក្នុងប្រព័ន្ធមើលថែព្យាបាលគាំទ្រឲ្យឯករាជ្យ(ការមើលថែព្យាបាលដោយទៅទទួលការព្យាបាលជំងឺផ្លូវចិត្ត)ឬពិការសតិបញ្ញា(ករណីមានសៀវភៅមើលថែព្យាបាលនិងចិញ្ចឹម)

2. អ្នកធាត់ដែលបំពេញបទដ្ឋាន(BMI ចាប់ពី30ឡើង)

* BMI = ទម្ងន់(kg)÷ កម្ពស់(m)÷ កម្ពស់(m)
* ស្តង់ដារនៃ BMI 30 ៖ កម្ពស់170cmទម្ងន់87kg, កម្ពស់160cmទម្ងន់77kg

## ◎ អំពីប្រព័ន្ធផ្តល់ជំនួយរងគ្រោះដោយផលប៉ះពាល់បន្ទាប់បន្សំ

នៅក្នុងប្រព័ន្ធផ្តល់ជំនួយ ក្នុងករណីកើតមានផលប៉ះពាល់សុខភាពដោយសារការចាក់វ៉ាក់សាំង ហើយត្រូវការការព្យាបាលនៅគ្រឹះស្ថានវេជ្ជសាស្ត្រ ឬមាននៅសល់ពិការភាពនោះនឹងអាចទទួលបានការផ្តល់ជំនួយ(ការឧបត្ថម្ភដូចជាថ្លៃព្យាបាល/ប្រាក់សោធននិវត្តន៍ពិការភាពជាដើម) ផ្អែកតាមច្បាប់ស្តីពីការចាក់វ៉ាក់សាំងបង្ការ។

| | |
|---|---|
| អំពីព័ត៌មានលម្អិតដូចជាប្រសិទ្ធភាព/សុវត្ថិភាពជាដើមរបស់វ៉ាក់សាំងកូវីដ-១៩ សូមមើលគេហទំព័រពិសេសអំពីវ៉ាក់សាំងរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី។ | ខុទ្ទកាល័យ កូរ៉ូណា វ៉ាក់សាំង ស្វែងរក |
| ប្រសិនបើមិនអាចមើលគេហទំព័របាន សូមប្រឹក្សាជាមួយរដ្ឋបាលមូលដ្ឋាន។ | |

## ◎ ដើម្បីទទួលការចាក់វ៉ាក់សាំង ចាំបាច់ត្រូវមានការព្រមព្រៀងរបស់សាមីខ្លួន

ចំពោះអ្នកដែលបច្ចុប្បន្នកំពុងព្យាបាលជំងឺអ្វីមួយ ឬមានការបារម្ភពីការចាក់វ៉ាក់សាំងដូចជាស្ថានភាពសុខភាពជាដើម សូមប្រឹក្សាជាមួយគ្រូពេទ្យក្នុងតំបន់ជាដើម រួចសឹមពិចារណាថាតើគួរទទួលការចាក់វ៉ាក់សាំងឬទេ។

## ◎ អំពីការចាក់វ៉ាក់សាំងនៅទីតាំងដែលគ្មានការចុះបញ្ជីស្នាក់នៅ

ចំពោះអ្នកដែលទទួលការចាក់វ៉ាក់សាំងនៅគ្រឹះស្ថានវេជ្ជសាស្ត្រឬមណ្ឌលដែលកំពុងសម្រាកព្យាបាល/ស្នាក់នៅ ➡ សូមប្រឹក្សាជាមួយគ្រឹះស្ថានវេជ្ជសាស្ត្រ/មណ្ឌល

ចំពោះអ្នកដែលទទួលការចាក់វ៉ាក់សាំងនៅគ្រឹះស្ថានវេជ្ជសាស្ត្រដែលកំពុងព្យាបាលដោយសារជំងឺប្រចាំកាយ ➡ សូមប្រឹក្សាជាមួយគ្រឹះស្ថានវេជ្ជសាស្ត្រ

ចំពោះអ្នកដែលមិនបានផ្ទេរការចុះបញ្ជីស្នាក់នៅហើយចង់ចាក់នៅតំបន់ដែលកំពុងស្នាក់នៅជាក់ស្តែង
➡ សូមសាកសួរទៅបញ្ជរការិយាល័យប្រឹក្សារបស់រដ្ឋបាលមូលដ្ឋានដែលស្នាក់នៅជាក់ស្តែង។ អាចមានករណីដែលអាចទទួលការចាក់នៅតំបន់ដែលស្នាក់នៅបាន។

អ្នកក៏អាចពិនិត្យមើលតាមគេហទំព័រអំពីវ៉ាក់សាំងកូវីដ-១៩ គឺ covid 19 vaccine navi ផងដែរ។

---

សាកសួរព័ត៌មាន
អំពីការកក់ទុកការចាក់វ៉ាក់សាំង
អំពីការប្រឹក្សាពីការចាក់វ៉ាក់សាំង
➡មជ្ឈមណ្ឌលសាកសួរព័ត៌មានតាមទូរសព្ទ នៃក្រុងមិតុយ៉ុ (មិតុយ៉ុ) **:0875-63-3104**
(ម៉ោង **8:30 ដល់ 17:30** ＊ លើកលែងថ្ងៃអាទិត្យ ថ្ងៃបុណ្យជាតិ)
ទំនាក់ទំនងសាកសួរព័ត៌មានសម្រាប់អ្នកពិការត្រចៀក **FAX 0875-63-8333**

អំពីផលរំខាន
➡មជ្ឈមណ្ឌលសាកសួរព័ត៌មានតាមទូរសព្ទ នៃខេត្តកាហ្កាវ៉ា **:0570-009-550**
(ម៉ោង **9:00 ដល់17:30** ＊ទាំងថ្ងៃសៅរ៍អាទិត្យនិងបុណ្យជាតិ)